ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

មីនា ២០០៥ / March 2005

កញ្ញា អ៊ុច ចំន្ទតារានី / **Ms. Ouch Chandarany**

លោកស្រី ប៉ុន ដូរីណា / **Ms. Pon Dorina**

លោក ហ៊ីង វុត្ថា / **Mr. Hing Vutha**

លោក ភីម រុនស៊ីណារិទ្ធិ / **Mr. Phim Runsinarith**

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា
# Main Economic Activities of Cambodia

នៅត្រីមាសទី៤ ២០០៤ (ដល់ខែវិច្ឆិកា) វិនិយោគសរុបទាំងសាធារណៈ និងឯកជន មាន ៤០លានដុល្លារ (៣៦%តិចជាងរយៈពេលដូចគ្នាឆ្នាំមុន) ក្នុងនេះវិនិយោគសាធារណៈថយចុះ ២៦% (ដល់ ៣០លានដុល្លារ) និង វិនិយោគឯកជនថយចុះ ៥៥% (វិនិយោគខាងសេវាកម្មចុះដល់សូន្យ) ។

In the fourth quarter of 2004 (up to November), total public and private investment amounted to $40 million, 36 percent less than during the same period of 2003. Public investment accounted for $30 million, a decrease of 26 percent. Private investment made up about $10 million, a drop of 55 percent. Private investment in the service sector dropped from $18.1 million to nil, while in industry it increased from $3.9 million to $10 million. From January to November 2004, total investment reached $505.5 million, 5 percent less than a year ago, public investment decreasing by 8 percent and private by 2 percent.

**Public Investment and Private Investment**
(millions of dollars)




* *Up to November 2004*
*Note: Provisional data for January–November 2004 (Including expansion projects).*
Source: Council for the Development of Cambodia and MEF

នៅត្រីមាសទី៤ ២០០៤ ភ្ញៀវបរទេសចូលតាមផ្លូវអាកាស គោក និងទឹក មាន ៣១០.៩៨៩នាក់ រឺ ៣៦,៤% ខ្ពស់ជាងត្រីមាសមុន និង ៣៤,៨% ខ្ពស់ជាងត្រីមាសទី៤ឆ្នាំមុន ក្នុងនេះភ្ញៀវចូលតាមយន្តហោះកើន ៣២% ដល់ ២០១.៥០៤នាក់ ។ ភ្ញៀវចូលសរុបនៅឆ្នាំ២០០៤ គឺ ៩៨៧.១៥៤នាក់ ធៀបនឹង ៧០១.០១៤នាក់កាលពីឆ្នាំ២០០៣ ។

In the fourth quarter of 2004, foreign visitors entering Cambodia by air, land and boat amounted to 310,989 persons, 36.4 percent more than in the preceding quarter and 34.8 percent more than in the same quarter of 2003. Compared to the fourth quarter of 2003, foreign visitors arriving by air rose by 32 percent to 201,504 persons and by land and boat rose by about 41 percent to 109,485 persons. In 2004, the number of foreign visitors to Cambodia totalled 987,154 persons, compared to 701,014 in 2003.

**Foreign Visitor Arrivals to Cambodia by Air, Land and Boat** (thousands of persons)




*Note: Provisional data for 2004.*
Source: Ministry of Tourism

នៅត្រីមាសទី៤ ២០០៤ តំលៃគំរោងសាងសង់នៅភ្នំពេញឡើងដល់ ៦៤,១ លានដុល្លារ រឺ ១៨%ទាបជាងត្រីមាសទី៣។ នៅឆ្នាំ២០០៤ តំលៃគំរោងសាងសង់អនុម័តដោយក្រុងភ្នំពេញមាន ២៦៣,៤លានដុល្លារ (កើន ១១% ធៀបនឹង ២០០៣) ក្នុងនេះផ្ទះល្វែងមានចំណែកធំជាងគេដល់ ១៦៧,៦ លានដុល្លារ (១១៦,៧លានដុល្លារកាលពី ២០០៣) ឯភូមិគ្រឹះមានកំណើន ៤៥% ដល់ ៣០,៣លានដុល្លារ, ប៉ុន្តែសំណង់ផ្សេងទៀតថយចុះ ៣៤,៥%។

In the fourth quarter of 2004, the value of construction projects approved in Phnom Penh amounted to $64.1 million, 18 percent less than in the third quarter. In 2004, the value of construction projects approved by the municipality totalled $263.4 million, an increase of 11 percent compared to 2003. Apartment construction continued to account for the largest share, rising to $167.6 million from $116.7 million in 2003. Mansion construction rose by 45 percent to $30.3 million. Other construction activities, however, declined by 34.5 percent to $65.6 million during this period.

**Value of Construction Projects Approved in Phnom Penh**




Source: Department of Cadastre and Geography, Municipality of Phnom Penh.

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

ថ្លៃសាំងនៅភ្នំពេញ សៀមរាប និងបាត់ដំបង គ្មានការប្រែប្រួលអស់៣ខែមកហើយ ដោយលក់បាន ៣.០៥០រៀល/លីត្រ នៅភ្នំពេញ និងសៀមរាប, ឯនៅបាត់ដំបង វាថោកជាងភ្នំពេញ និងសៀមរាប ៥០រៀល/លីត្រ នៅខែកុម្ភៈ២០០៥ នេះ ។

The price of gasoline in Phnom Penh, Siem Reap and Battambang remained unchanged for the third consecutive month. It was 3,050 riels/litre in Phnom Penh and Siem Reap. In Battambang, the price was 50 riels per litre lower than in the other two areas.

**Price of Gasoline in Battambang, Siem Reap and Phnom Penh** (riels/litre)




*Source: CDRI and National Institute of Statistics*

នៅខែកុម្ភៈ ២០០៥ អង្ករលេខ២ នៅភ្នំពេញថ្លៃ ៩៤០រៀល/គក្រ ធៀប នឹង ៩៣០រៀល/គក្រ នៅខែមករា និងប្រហែលបន្តឡើងទៀតនៅខែក្រោយ ពីព្រោះមានឈ្មួញថៃ និងវៀតណាមជាច្រើន មកប្រមូលទិញវាពី កម្ពុជា ជាពិសេសនៅបាត់ដំបង បន្ទាយមានជ័យ ស្វាយរៀង កំពង់ចាម ។ អង្ករលេខ២ នេះ ឡើងថ្លៃ ២%ធៀបនឹងខែកុម្ភៈ ២០០៤ និងឡើងថ្លៃ ២,៧%ធៀបនឹងខែកុម្ភៈ ២០០៣ ។

In February 2005, the price of second quality rice in Phnom Penh was 940 riels/kg, compared to 930 riels/kg in January. The price of rice will probably continue to rise next month, because there are many Thai and Vietnamese traders collecting rice from Cambodia, especially in Battambang, Banteay Meanchey, Svay Rieng, Prey Veng and Kompong Cham provinces, according to Cambodian rice wholesalers. The price of second quality rice rose by 2 percent over February 2004 and 2.7 percent over the same month in 2003.

**Price of Second Quality Rice in Phnom Penh**




*Note: The latest data available are for February 2005.*
Source: CDRI and National Institute of Statistics

នៅត្រីមាសទី៤ ២០០៤ មាសបន្តឡើងថ្លៃដល់ ៤៧ដុល្លារ/ជី វី ឡើងថ្លៃ ១,៥%ពីត្រីមាសទី៣ ទៅ ទី៤ ២០០៤ គឺលឿនជាងកាលពីត្រីមាសទី១ ទៅទី២ ដែលឡើងត្រឹម ០,៧% ។ម្យ៉ាងទៀត វាបានឡើងថ្លៃ ៦% ធៀបនឹងត្រីមាសទី៤ ២០០៣ ដែលកាលណោះវាលក់ថ្លៃ ៤៤,៤០ដុល្លារ/ជី ។

The price of gold continued to rise in Phnom Penh, reaching $47 per *chi* in the fourth quarter of 2004. It rose by 1.5 percent over the third and fourth quarters, faster than over the second and third quarters, which experienced a 0.7 percent increase. Compared to the fourth quarter of 2003, the price of gold rose by 6 percent from $44.40 per *chi*.

**Gold Price in Phnom Penh**
(US$ per chi)




*Source: Ministry of Economy and Finance and CDRI*

# ស្ថានភាពអត្រាប្តូរប្រាក់និងរូបិយវត្ថុ
# Exchange Rate and Monetary Developments

អត្រាផ្តូរប្រាក់ទីផ្សារ រៀល-ដុល្លារ សឹងគ្មានការប្រែប្រួលពីខែមករា-កុម្ភៈ ២០០៥ ។ នៅខែកុម្ភៈ អត្រាប្តូរគឺ ៤.០៤០រៀល/ដុល្លារ ធៀបនឹង ៤.០៣៩រៀល/ដុល្លារនៅខែមករា ២០០៥ និង ៣.៩៨៣រៀល/ដុល្លារនៅខែកុម្ភៈ ២០០៤ ។

The market exchange rate between the Cambodian riel and the US dollar in Phnom Penh remained almost unchanged over January–February 2005. One dollar traded at 4,040 riels in February 2005, compared to 4,039 riels in January and 3,983 riels in February 2004.

**Riels per US Dollar**
(market and official rates)




*Source: National Bank of Cambodia and CDRI*

ប្រាក់រៀលបន្តចុះថ្លៃទល់នឹងប្រាក់បាតថៃដោយប្តូរបាន ១០៤,៩រៀល/បាត នៅខែកុម្ភៈ ២០០៥ រឺ ចុះថ្លៃ ០,៨%ធៀបនឹងខែមុន ។ ក្នុងពេលដដែល ប្រាក់រៀលឡើងថ្លៃ ០,៨%ទល់នឹងប្រាក់ដុងវៀតណាមដោយប្តូរបាន ២៥,៣រៀល/១០០ដុង ធៀបនឹង ២៥,៥រៀល/១០០ដុងកាលពីខែមករា ។

The riel continued to depreciate against the Thai baht, trading at 104.9 riels/baht in February 2005, a depreciation of 0.8 percent compared to the preceding month. In the meantime, the riel appreciated by 0.8 percent against the Vietnamese dong. 100 dongs were priced at 25.3 riels in February 2005, down from 25.5 riels in January.

**Riels per Thai Baht and 100 Vietnamese Dong**




*Source: CDRI and the Economist*

បន្ទាប់ពីបានថយចុះនៅខែវិច្ឆិកា រូបិយវត្ថុទូទៅ M2 កើនឡើងនៅខែធ្នូ ២០០៤ ដល់ ៤.៣២៩,៣ពាន់លានរៀល រឺ ០,៩%ច្រើនជាងនៅខែវិច្ឆិកា ។ សមាសភាគជារៀល ដែលមានប្រាក់រៀលនៅក្រៅធនាគារ និងប្រាក់បញ្ញើចរន្ត ប្រាក់សញ្ញើយ និងប្រាក់បញ្ញើមានកាលកំណត់ កើន ៤,៤% ដល់ ១.២៥០,២ពាន់លានរៀល ។ ប៉ុន្តែប្រាក់បញ្ញើជារូបិយវត្ថុបរទេស ថយចុះ ០,៧% ដល់ ៧៦៣,៨លានដុល្លារ ។ ធៀបនឹងខែធ្នូ ២០០៣ រូបិយវត្ថុទូទៅ កើន ៣០%, ក្នុងនេះ ប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើន ៣៣,៣% ។

Total liquidity rose in December 2004, after declining in the preceding month. Liquidity amounted to 4,329.3 billion riels in December, 0.9 percent more than in November. The riel component, which comprises riels outside banks plus demand, time and saving deposits, rose by 4.4 percent to 1,250.2 billion riels. In contrast, foreign currency deposits declined by 0.7 percent to $763.8 million (3,079.1 billion riels). Compared to December 2003, liquidity rose by 30 percent, foreign currency deposits increasing by 33.3 percent and the riel component by 22.7 percent.

**Liquidity through the Banking System**
(billion riels)




*Note: The latest data available are for December 2004 (provisional data).*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

នៅត្រីមាសទី ៤ ២០០៤ ការនាំចេញរបស់កម្ពុជាមាន ៥៤៥,១លានដុល្លារ គឺថយចុះ ១៨,៥%ធៀបនឹងត្រីមាសទី៣ ដោយសារការនាំចេញទៅUS បាន ថយចុះ ១៧,៣% ដល់ ៣២៥,៣លានដុល្លារ និងទៅ EU ថយចុះ ២០,៨% ដល់ ១៥៩,៤លានដុល្លារ ប៉ុន្តែការនាំចេញទៅប្រទេសអាស៊ានបានកើនឡើង ១០,២% ដល់ ១៧,២លានដុល្លារ ។ នៅឆ្នាំ២០០៤ ការនាំចេញសរុប របស់កម្ពុជាគឺ ២.១០៨,២លានដុល្លារ រឺ ២៣,៤%ច្រើនជាងឆ្នាំ២០០៣ ។

In the last quarter of 2004, Cambodian exports were $545.1 million, a decrease of 18.5 percent from the third quarter. During this period, exports to the US and EU experienced a decline, while exports to ASEAN countries rose. Exports to the US and EU markets declined by 17.3 percent to $325.3 million and by 20.8 percent to $159.4 million, respectively. Exports to ASEAN increased by 10.2 percent to $17.2 million. According to the Customs and Excise Department, Cambodia’s total exports amounted to $2,108.2 million in 2004, 23.4 percent more than in 2003.

**Cambodia's Exports by Destination**
(millions of dollars)




*Note: The latest data available are for December 2004.*
Source: Customs and Excise Department

នៅត្រីមាសទី៤ ២០០៤ ការនាំចូលស៊ីម៉ង់ត៍ឡើងដល់ ៣៨,៤ពាន់លានរៀល (៩,៥លានដុល្លារ) រឺ ១,៧% ខ្ពស់ជាងត្រីមាសទី៣ ។ ក្នុងពេលដដែល ដែក នាំចូលកើន ៧៦,៤% ដល់ ១៩ពាន់លានរៀល (៤,៧លានដុល្លារ) ។ នៅឆ្នាំ ២០០៤ ការនាំចូលសរុបនូវ ស៊ីម៉ង់ត៍កើន ៨%ដល់ ១៥៨,៧ពាន់លានរៀល (៣៩,៤លានដុល្លារ) និង ដែកកើន ១៦,៦% ដល់ ៧៦,២ពាន់លានរៀល (១៩លានដុល្លារ) បើធៀបនឹងកាលពីមួយឆ្នាំមុន ។

Imports of cement increased to 38.4 billion riels ($9.5 million) in the fourth quarter of 2004, 1.7 percent higher than in the third quarter. At the same time, imports of steel rose by 76.4 percent to 19 billion riels ($4.7 million). In 2004, total imports of cement and steel rose by 8 percent to 158.7 billion riels ($39.4 million) and 16.6 percent to 76.2 billion riels ($19 million), respectively, compared to one year earlier.

**Imports of Construction Materials**
(billion riels)




Note: The latest data available are for December 2004.
(Excluding public sector imports.)
*Source: Customs and Excise Department*

នៅត្រីមាសទី៤ ២០០៤ ម៉ាស៊ូតនាំចូល មាន ៩៤,២ពាន់លានរៀល (២៣,៣ លានដុល្លារ) រឺ ១៤%តិចជាងនៅត្រីមាសទី៣ ប៉ុន្តែ សាំងនាំចូល កើន ១៩% ដល់ ៣១,៤ពាន់លានរៀល (៧,៨លានដុល្លារ) ។ នៅឆ្នាំ២០០៤ កម្ពុជាបាន នាំចូលម៉ាស៊ូត ៤៣៤,២ពាន់លាន់រៀល (១០៧,៨លានដុល្លារ) រឺ ០,៨%តិច ជាងឆ្នាំ២០០៣ ចំណែកឯការនាំចូលសាំង ចុះដល់ ១២០ពាន់លានរៀល (២៩,៨លានដុល្លារ) ធៀបនឹង ១៣១,៦ពាន់លានរៀល (៣៣លានដុល្លារ) កាលពីឆ្នាំ២០០៣ ។

Imports of diesel amounted to 94.2 billion riels ($23.3 million) in the fourth quarter of 2004, 14 percent less than in the third quarter. Conversely, imports of gasoline rose by 19 percent to 31.4 billion riels ($7.8 million). In 2004, Cambodia imported diesel worth 434.2 billion riels ($107.8 million), 0.8 percent less than in 2003. Meanwhile, gasoline imports fell to 120 billion riels ($29.8 million), down from 131.6 billion riels ($33 million).

**Value of Imports of Petroleum Products**
(billion riels)




Note: The latest data available are for December 2004.
(Excluding public sector imports.)
*Source: Customs and Excise Department*

# ប្រភពនិងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

យោងតាម CDC កម្ពុជាទទួលបានជំនួយឥតសំណង ៤.១១១,៤លានដុល្លារ ពីឆ្នាំ១៩៩២-២០០៣ ។ ក្នុងនេះ ៥០% (២.០៥៤,៧លានដុល្លារ) សំរាប់សហប្រតិបត្តិការបច្ចេកទេសជាទូទៅ, ២៤% (៩៨៨,៩លាន) ជាជំនួយលើគំរោងវិនិយោគ ១៥,៣%(៦៣០,៩លាន) ជាជំនួយស្បៀងអាហារ, ៦,៨% (២៨០,២លាន) ជាសហប្រតិបត្តិការបច្ចេកទេសទាក់ទិននឹងវិនិយោគ និង ៣,៨% (១៥៥,៣លាន) ជាការទ្រទ្រង់ដល់ថវិកា និងជញ្ជីងទូទាត់ ។

According to the Council for the Development of Cambodia, Cambodia received grants worth $4,111.4 million disbursed during 1992–2003. Of this, 50 percent ($2,054.7 million) was devoted to free-standing technical cooperation, 24 percent ($988.9 million) to investment project assistance, 15.3 percent ($630.9 million) to food aid, emergency and relief assistance, 6.8 percent ($280.2 million) to investment-related technical cooperation and 3.8 percent ($155.3 million) to budgetary aid/balance of payments support.

**Grants by Type of Assistance 1992–2003**
(millions of dollars)




*Provisional data for 2003.*
Source: Council for the Development of Cambodia

ពីឆ្នាំ១៩៩២-២០០៣ មានទឹកប្រាក់សរុប ៥០២,៤លានដុល្លារ (៩,៧%នៃការបើកផ្ដល់ជំនួយសរុប) បានប្រើប្រាស់សំរាប់ការគ្រប់គ្រងសេដ្ឋកិច្ច ។ នៅឆ្នាំ២០០៣ មានផ្ដល់ ៣៤លានដុល្លារសំរាប់ទ្រទ្រង់ដល់វិស័យនេះ ដែលរួមមាន គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច, គោលនយោបាយ និងផែនការសារពើពន្ធ, គោលនយោបាយ និងផែនការរូបិយវត្ថុ, និងគោលនយោបាយ និងផែនការខាងការងារ/ជីវភាពរស់នៅ ។

During 1992–2003, a total of $502.4 million, 9.7 percent of total aid disbursements, was used for economic management. In 2003, $34 million was provided to support this sector, which includes macro-economic policy and planning, fiscal policy and planning, monetary policy and planning and employment/livelihood policy and planning.

**External Development Assistance Disbursements for Economic Management 1992–2003**
(millions of dollars)




*Provisional data for 2003.*
Source: Council for the Development of Cambodia

យោងតាមក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ការបើកផ្ដល់ជំនួយសំរាប់រដ្ឋបាលខាងអភិវឌ្ឍន៏ ពីឆ្នាំ១៩៩២-២០០៣ មាន ៥៥៣,៦លានដុល្លារ រឺ ១០,៧% នៃការបើកផ្ដល់សរុប ។ ក្នុងនេះ ២០,៧លានដុល្លារបានប្រើប្រាស់សំរាប់ឆ្នាំ ១៩៩២-១៩៩៣, ៣៥៥,៨លានដុល្លារសំរាប់ឆ្នាំ១៩៩៤-១៩៩៨ និង ១៧៧,១លានដុល្លារសំរាប់ឆ្នាំ១៩៩៩-២០០៣ ។

According to the Council for the Development of Cambodia, assistance disbursements for development administration during 1992–2003 amounted to $553.6 million, representing 10.7 percent of total disbursements. Of this, $20.7 million was used for 1992–1993, $355.8 million for 1994–1998 and $177.1 million for 1999–2003.

**External Development Assistance Disbursements for Development Administration 1992–2003**
(millions of dollars)




*Provisional data for 2003.*
Source: Council for the Development of Cambodia

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

ពីខែមករា-វិច្ឆិកា ២០០៤ ថវិកាចរន្តរបស់កម្ពុជា មានអតិរេក ៦១៣ពាន់លានរៀល ធៀបនឹង ១៨៦ពាន់លានរៀលក្នុងរយៈពេលដូចគ្នាឆ្នាំ២០០៣។ ក្នុងពេលនេះដែរ ចំណូលចរន្តឡើងដល់ ៨២%នៃផែនការក្នុងច្បាប់ថវិកាឆ្នាំ ២០០៤, ចំណែកឯចំណាយចរន្តបានតែ ៥៨%នៃផែនការប៉ុណ្ណោះ ។

Over the period January–November 2004, Cambodia's current budget operations exhibited a surplus of 613 billion riels, compared to 186 billion riels in the same period of 2003. During this period, current revenues reached 82 percent of the target in the 2004 budget law, while current expenditure achieved only 58 percent of the target.

**Current Budget Operations**
(billion riels)




*Note: Provisional for January–November 2004.*
Source: Ministry of Economy and Finance

ពីខែមករា-វិច្ឆិកា ២០០៤ ចំនូលថវិកាចរន្តកម្ពុជា មាន ១.៧១៣ពាន់លានរៀល រឺ ១៦%ច្រើនជាងរយៈពេលដូចគ្នាឆ្នាំ២០០៣។ ក្នុងនេះចំនូលពន្ធក្នុងស្រុកកើន ២៨,៥% ដល់ ៩០២,៥ពាន់លានរៀល, និងពន្ធគយកើន ១៧% ដល់ ៤១៣,៤ពាន់លានរៀល។ ប៉ុន្តែចំណូលមិនមែនពន្ធ ថយចុះ ៥% ដល់ ៣៩៧ពាន់លានរៀល រឺត្រឹម ៦៣%នៃផែនការ។ ក្នុងនេះ ចំនូលពីខាងព្រៃឈើ និងអាកាសចរស៊ីវិល បានតែ ៥% និង ២៦%នៃផែនការប៉ុណ្ណោះ ។

From January to November 2004, current budget revenue amounted to 1,713 billion riels, 16 percent more than in the same period of 2003 and 82 percent of the target in the 2004 budget law. Revenues from domestic taxes and custom duties rose by 28.5 percent to 902.5 billion riels and by 17 percent to 413.4 billion riels, respectively. Non-tax revenue, however, declined by 5 percent to 397 billion riels, reaching just 63 percent of the target. Of this, revenues from forest exploitation and civil aviation achieved just 5 percent and 26 percent of their targets, respectively.

**Current Budget Revenue**
(billion riels)




*Note: Provisional for January–November 2004.*
Source: Ministry of Economy and Finance

ពីខែមករា-វិច្ឆិកា ២០០៤ ចំនាយថវិកាចរន្តឡើងដល់ ១.១០០ពាន់លានរៀល (៥៨%នៃផែនការ) រឺ ១៤,៥%តិចជាងរយៈពេលដូចគ្នាឆ្នាំ២០០៣។ ក្នុងនេះ ៣៧៨ពាន់លានចំណាយលើរដ្ឋបាលសង្គមកិច្ច, ២៨៦,៥ពាន់លានលើការពារជាតិនិងសន្តិសុខ, ១៧៩,៦ពាន់លានលើរដ្ឋបាលទូទៅ, ៩២,៦ ពាន់លានលើរដ្ឋបាលសេដ្ឋកិច្ច និង ១៦៣,២ពាន់លានលើវិស័យឯទៀត ។

Between January and November 2004, current budget expenditure reached 1,100 billion riels (58 percent of the target), 14.5 percent less than in the same period of 2003. Of the total, 378 billion riels was expended on social administration (a 7.1 percent decrease), 286.5 billion riels on defence and security (an 11.6 percent decrease), 179.6 billion riels on general administration (a decrease of 30.7 percent), 92.6 billion riels on economic administration (a drop of 16.5 percent), and 163.2 billion riels on other (a drop of 12 percent).

**Current Budget Expenditure**
(billion riels)




*Note: Provisional for January–November 2004.*
Source: Ministry of Economy and Finance

# សកម្មភាពសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

ជញ្ជីងពាណិជ្ជកម្ម US សំរាប់ទំនិញនិងសេវានៅឆ្នាំ២០០៣ មានឱនភាពធំបំផុតក្នុងរយះ ៧ឆ្នាំ ដល់ ៤៩៦,៥១ពាន់លានដុល្លារ គឺប្រហែល ២០%ខ្ពស់ជាងឆ្នាំមុន និង ៣០%ខ្ពស់ជាងមធ្យមភាគក្នុងរយះ៥ឆ្នាំ១៩៩៩-២០០៣។ ជញ្ជីងពាណិជ្ជកម្ម EU និងជប៉ុន មានលំនាំដូចគ្នាក្នុងរយះ ៣ឆ្នាំ។ EU មានអតិរេកខ្ពស់បំផុតដល់ ១៤១,១៤ពាន់លានដុល្លារ រឺ ១%ខ្ពស់ជាងឆ្នាំមុន រីឯអតិរេកជប៉ុនកើន៤០%ខ្ពស់ជាងឆ្នាំមុនឡើងដល់ ៧២,៤៩ពាន់លានដុល្លារ។

The United States balance of trade for goods and services in 2003 reached the greatest deficit in seven years at $496.51 billion. This amount is about 20 per cent higher than in the previous year and 30 per cent higher than the five-year average for 1999–2003. The trade balances of EU and Japan reveal a similar pattern for three years. The EU reached a record surplus at $141.14 billion, 1 percent higher than the previous year, while Japan's surplus grew about 40 per cent from the previous year, reaching $72.49 billion.

**Balance on Goods and Services in the US, Europe and Japan** (billions of US$)




*Source: International Financial Statistics, December 2004*

ជញ្ជីងលើទំនិញ និងសេវា ក្នុងប្រទេសទាំង ៣ មានរូបភាពចំរុះ ។ អតិរេករបស់ចិនថយចុះបន្តិច (ធៀបឆ្នាំ២០០២) ដល់ ៣៦,០៧ពាន់លានដុល្លារ ។ ហុងកុងមានអតិរេកកើនឡើងដល់ ១៤,២៣ពាន់លានដុល្លារ។ កូរ៉េខាងត្បូងក្រោយថយអតិរេកយ៉ាងទៀងទាត់ អស់ ៤ឆ្នាំតាំងពីឆ្នាំ១៩៩៨មក បានកើនអតិរេកមួយជាពីរវិញ ឡើងដល់ ១៤,៥៣ពាន់លានដុល្លារនៅឆ្នាំ២០០៣ ។

The balance on goods and services in these three economies presents a mixed picture. China's surplus declined slightly from 2002 to $36.07 billion. Hong Kong recorded an increased surplus of $14.23 billion. South Korea, after a steady decline in its surplus for four years from 1998, doubled its surplus of 2002 to reach $14.53 billion in 2003.

**Balance on Goods and Services in China, Hong Kong and South Korea** (billion US$)




*Source: International Financial Statistics, December 2004*

សិង្ហបុរីមានកំណើនអតិរេកយ៉ាងទៀងទាត់ ដែលឡើងខ្ពស់បំផុតដល់ ៣០,៤៥ពាន់លានដុល្លារនៅឆ្នាំ២០០៣ រឺ ៥២%ខ្ពស់ជាងឆ្នាំមុន។ ម៉ាឡេស៊ីមានកំណើនធំណាស់ដល់ ៣១% ពីឆ្នាំ២០០២-២០០៣ ដោយឡើងដល់ ២១,៧៥ពាន់លានដុល្លារ ដែលជាកំរិតខ្ពស់បំផុតក្នុងរយះ៧ឆ្នាំ និងដែលទាញឡើងមកវិញបាននូវការថយចុះយ៉ាងទៀងទាត់តាំងពីឆ្នាំ១៩៩៩ មក។ ថៃសំរេចបានកំណើនអតិរេកតូចមួយ ត្រឹម ៨,៨ពាន់លានដុល្លារ ក្រោយពីបានធ្លាក់ចុះអស់មួយរយះតាំងពីឆ្នាំ១៩៩៨ មក ។

Singapore has experienced a steady growth in surplus and reached a record surplus of $30.45 billion in 2003, 52 per cent higher than the previous year. Malaysia recorded a considerable increase by 31 per cent over 2002-03 reaching $21.75 billion, the highest level in seven years, reversing the steady decline since 1999. Thailand achieved a slight increase in its surplus to $8.8 billion, after a period of decline since 1998.

**Balance on Goods and Services in Some ASEAN Countries** (billion US$)




*Source: International Financial Statistics, December 2004*

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation rates in Selected Economic Partners of Cambodia

នៅខែធ្នូ សន្ទស្សន៍ទំនិញប្រើប្រាស់ CPI ជប៉ុន មានកំរិត 0,២% ខ្ពស់ជាងខែដូចគ្នាឆ្នាំ២00៣ ប៉ុន្តែថយចុះ 0,៦% ទាបជាងខែវិច្ឆិកា ។ ធនាគារជាតិជប៉ុនបានសន្យាបន្តអនុវត្តនយោបាយពង្រីកសាច់ប្រាក់រហូតដល់ CPI ឈប់ធ្លាក់ចុះ។ ក្នុងរយៈពេលដដែល អតិផរណានៅ EU មានអត្រាកំណើនប្រចាំឆ្នាំកើនបន្តិចដល់ ២,៤% ឯនៅ US វាមានកំរិត ៣,៣% គឺទាបជាងខែមុនបន្តិច ។

Japan's CPI in December was 0.2 percent higher than in the same month of 2003, but was down 0.6 percent from November. The Bank of Japan has pledged to keep its current expansionary policy in place until the CPI stops falling. During the same period, the inflation rate in the euro economies rose slightly to 2.4 percent, while in the US it ran at an annual rate of 3.3 percent, slightly down from the previous month.

**Inflation Rates in the US, Europe and Japan**
(percentage change over previous year)




*Note: The latest data available are for December 2004.*
Sources: IMF and the *Economist* (19–25 February 2005)

អតិផរណាថ្លៃទំនិញប្រើប្រាស់នៅចិន ស្ទុះឡើងដល់ ២,៨%ក្នុងឆ្នាំ២00៤ គិតដល់ខែធ្នូ ធៀបនឹងកំរិត ២,៤%បើគិតត្រឹមខែវិច្ឆិកា ដោយសារតំរូវការក្នុងស្រុកកើនឡើងច្រើន។ នៅហុងកុង អតិផរណាមានអត្រាកំនើនប្រចាំឆ្នាំ 0,២% គឺគ្មានប្រែប្រួលអ្វីទេធៀបនឹងខែវិច្ឆិកា ។ អតិផរណានៅកូរ៉េខាងត្បូង មានអត្រាប្រចាំឆ្នាំថយចុះបន្តិចនៅខែធ្នូ បើធៀបនឹងខែវិច្ឆិកា ។

Consumer-price inflation in China accelerated to 2.8 percent in the year to December, from 2.4 percent in the year to November. This was due to stronger domestic demand. In Hong Kong inflation was running at an annual rate of 0.2 percent, showing no change from November. Inflation in South Korea registered a small annual decline in December 2004 compared to November.

**Inflation Rates in China, Hong Kong and South Korea** (percentage change over previous year)




*Note: The latest data available are for December 2004.*
Sources: IMF and the *Economist* (Feb. 19-25, 2005)

នៅខែធ្នូ ២00៤ អតិផរណាថ្លៃទំនិញប្រើប្រាស់នៅម៉ាឡេស៊ី នៅខ្ពស់ដដែល ដោយមានអត្រាកំណើនប្រចាំឆ្នាំ ២,១% ។ យោងតាម Bloomberg News រឿងនេះមួយភាគធំគឺដោយសារ កំណើនថ្លៃថាមពល និងតំរូវការប្រើប្រាស់ ។ ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរីកើន ១,៥%ក្នុងឆ្នាំ២00៤ គិតដល់ខែធ្នូ រីឯនៅថៃ វាកើន ២,៩% គឺថយចុះបន្តិចបើធៀបនឹងខែវិច្ឆិកា ។

In December 2004, consumer price inflation in Malaysia remained high, running at an annual rate of 2.1 percent. According to Bloomberg News, this was due largely to higher costs of energy and stronger consumer sentiment. Consumer prices in Singapore rose 1.5 percent in the year to December, while in Thailand it rose by 2.9 percent, a slight decline compared to November.

**Inflation Rates in Selected ASEAN Countries**
(percentage change over previous year)




*Note: The latest data available on Singapore and Thailand are for November 2004.*
Sources: IMF and the *Economist* (15–21 January 2005)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

# Exchange Rates in World Markets

នៅខែកុម្ភៈ ដុល្លារUS នៅនឹង បើធៀបនឹងប្រាក់យ៉េនជប៉ុន ដោយប្តូរបាន ១០៤.៩៦យ៉េន/ដុល្លារ ធៀបនឹង ១០៣.៣៤យ៉េន/ដុល្លារនៅខែមករា ។ ការចុះថ្លៃប្រាក់យ៉េនប្រហែលដោយសារ ការបន្ធូរនយោបាយរូបិយវត្ថុរបស់ធនាគារជាតិជប៉ុន និងការថយចុះ ផសស ជប៉ុន ។ ផ្ទុយទៅវិញ ដុល្លារUS បន្តឡើងថ្លៃធៀបនឹងប្រាក់អឺរ៉ូ ដោយប្តូរបាន ០,៧៧អឺរ៉ូ/ដុល្លារ ធៀបនឹង ០,៧៦អឺរ៉ូ/ដុល្លារ កាលពីមួយខែមុន ។

In February the US dollar was steady against the Japanese yen, trading at 104.96 yen, compared with 103.34 yen in January. The depreciation of the yen may is likely to be related to a more relaxed monetary policy of the Bank of Japan and the decline in Japan's GDP. In contrast, the dollar continued to appreciate against the euro, trading at 0.77 euros, compared to 0.76 a month earlier.

### Euro and Japanese Yen against US Dollar




*Note: Data are up to 28 February.*
Source: Federal Reserve Bank of New York

នៅខែកុម្ភៈ ដុល្លារហុងកុង បានចុះថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ៧.៧៩៩ដុល្លារហុងកុង/ដុល្លារUS ។ ផ្ទុយទៅវិញ ប្រាក់វ៉ុនកូរ៉េខាងត្បូង បន្តឡើងថ្លៃដល់ ១.០២៩.៧វ៉ុន/ដុល្លារ ។ ការចុះថ្លៃដុល្លារទល់នឹងវ៉ុន អាចទាក់ទិននឹងការវាយស្មានចុះឡើងថា ធនាគារកណ្តាលកូរ៉េខាងត្បូង អាចបន្ថយល្បឿនការទិញទ្រព្យសកម្មUS ហើយបែរទៅប្រើរូបិយវត្ថុផ្សេងទៀត ដើម្បីកសាងធនបំរុង ។

In February the Hong Kong dollar lost value against the US dollar, trading at 7.799 HK$/US$, a slight fall from the previous month. In contrast, the South Korean won continued to appreciate, reaching 1029.7 won/US$. The decline of the US dollar against the won may could be related to speculation that the South Korean central bank may slow purchases of US assets and use other currencies as reserves.

### South Korean Won and Hong Kong Dollar against US Dollar




*Note: Data are up to 28 February.*
Source: Federal Reserve Bank of New York

នៅខែកុម្ភៈ ប្រាក់បាតថៃបន្តឡើងថ្លៃដល់ ៣៨.៤៧បាត/ដុល្លារ ធៀបនឹង ៣៨.៧៣បាត/ដុល្លារនៅខែមករា ។ រឿងនេះឆ្លុះបញ្ចាំងជាសំខាន់ពីការបារម្ភថា ធនាគារជាតិនានានៅអាស៊ី អាចបោះបង់ដុល្លារ ទៅប្រើរូបិយវត្ថុផ្សេងទៀតដើម្បីកសាងធនបំរុង និងពីលំហូរមូលធនយ៉ាងច្រើនចូលថៃ ។ ក្នុងពេលដដែល ដុល្លារសិង្ហបុរីប្តូរបាន ១.៦៣៩ដុល្លារសិង្ហបុរី/ដុល្លារUS ជាមធ្យម ។

In February, the baht continued to appreciate, reaching 38.47 baht/US$ compared to 38.73 in January. This largely reflected the concern that Asian central banks might move out of the US dollar and use other currencies as reserves, as well as because of strong capital inflows into Thailand. During the same period, the Singapore dollar on average traded at 1.639 to the US dollar.

### Thai Baht and Singaporean Dollar against US Dollar




*Note: Data are up to 28 February 2005*
*Source: Federal Reserve Bank of New York*

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ
# Commodity Prices in World Markets

នៅខែកុម្ភៈ ថ្លៃអង្ករលេខ១ នៅផ្សារអន្តរជាតិក្រុងបាងកកគឺ ២៩៨,៣៣ ដុល្លារ/តោន រឺខ្ពស់ជាងខែមុនបន្តិច និងត្រូវជា ២២%ខ្ពស់ជាងថ្លៃមធ្យមក្នុងឆ្នាំ២០០៤។ សណ្តែកសៀងបន្តចុះថ្លៃដល់ ២១៥,១០ដុល្លារ/តោន រឺ ២៦% ទាបជាងថ្លៃមធ្យមក្នុងឆ្នាំ ។ ពោតនៅនឹងថ្លៃក្នុងរយៈ ៥ខែមកដល់ខែកុម្ភៈ ដោយលក់បាន ៩២,៩៨ដុល្លារ/តោន ។

The price of rice was $298.33 per ton in the Bangkok market in February, slightly higher than the previous month. This is about 22 per cent higher than the average price in 2004. The price of soybeans continues to decline and was $215.10 per ton in February, 26 percent lower than the average over the year. The maize price has remained stable in the five month period leading up to February, when it was sold at $92.98 per ton.

**International Prices of Rice, Soybeans and Maize** (US$/ton)




Source: Food and Agriculture Organisation (FAO)

សណ្តែកដីចុះថ្លៃបន្តិច ហើយនិន្នាការនេះអាចមើលឃើញច្បាស់តាំងពីខែមករា ២០០៤ មេ្លះ ។ នៅខែមករា ២០០៥ វាលក់បាន ៩៤០ដុល្លារ/តោន រឺប្រហែល ១%ទាបជាងកាលពីខែមុន និង ៣%ទាបជាងថ្លៃមធ្យមនៅឆ្នាំមុន ។ ប្រេងឆាចុះថ្លៃអស់ ៤ខែហើយ មកដល់ខែមករា ២០០៥ នេះ ដែលវាលក់បាន ៤០២ដុល្លារ/តោន ។ ថ្លៃលក់នេះ មានកំរិត ៥%ទាបជាងខែមុន និង ១៥%ទាបជាងថ្លៃមធ្យមនៅឆ្នាំ២០០៤ ។

The groundnut price has recorded a slight decline – a trend that is evident since January 2004. It is at $940 per ton in January, about 1 per cent lower than in the previous month and 3 per cent lower than the average price last year. Palm oil price has declined in the four month period leading up to January 2005 when it stood at $402 per ton. This is 5 per cent lower than the previous month and 15 per cent lower than the average in 2004.

**International Prices of Palm Oil and Groundnuts** (US$/ton)




Source: Food and Agriculture Organisation (FAO)

នៅខែកុម្ភៈ ប្រេងឆៅឡើងថ្លៃ ប៉ុន្តែប្រេងសាំងចុះថ្លៃ ។ ប្រេងឆៅនៅ ឌូបៃអាស៊ី មានថ្លៃលក់ប្រគល់ភ្លាម ៣៨,៨០ដុល្លារ/ធុង រឺ កំណើន ៣%ធៀបនឹងខែមុន និង ១៦%ខ្ពស់ជាងថ្លៃមធ្យមនៅឆ្នាំមុន។ ប្រេងសាំងចុះថ្លៃដល់ ៣២,២៦សេន/លីត្រ រឺ ប្រហែល ១%ទាបជាងខែមុន និង ៤%ខ្ពស់ជាងថ្លៃមធ្យមនៅឆ្នាំមុន ។

In February the price of crude oil rose, while the price of gasoline fell. The Asia Dubai fetch spot price of crude oil was $38.80 per barrel, a rise of 3 per cent from the previous month and 16 per cent above the average price over the last year. Gasoline fell to 32.26 cents per litre, about 1 per cent lower than the previous month, but about 4 per cent higher than the average price in the last year.

**Prices of Crude Oil and Gasoline**




*Note: Data are up to 25 January 2005*
*Sources: EIA and IEA*